# ព្រះរាជាណាចក្រកម្ពុជា

## ជាតិ សាសនា ព្រះមហាក្សត្រ

# កិច្ចព្រមព្រៀងរវាង
# រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹងកម្មករ-និយោជិត

យោងតាមស្ថានភាពរោងចក្រនាពេលបច្ចុប្បន្ន មានបញ្ហាខ្វះការបញ្ជាទិញ បានធ្វើឲ្យប៉ះពាល់ពាល់ដល់ខ្សែសង្វាក់ផលិតកម្ម ហេតុដូចនេះ រោងចក្របានទទួលការឯកភាពពីកម្មករ-និយោជិតទាំងអស់ដែលតំណាងដោយសហជីព និងប្រតិភូបុគ្គលិកដូចខាងក្រោម៖

១- កម្មករ-និយោជិតចំនួន ២៦៨នាក់ (ស្រីចំនួន ២៦៨នាក់) ត្រូវព្យួរកិច្ចសន្យាការងាររយៈពេល ១ខែ ១២ថ្ងៃ ចាប់ពីថ្ងៃ២០ ខែវិច្ឆិកា ឆ្នាំ២០២៤ រហូតដល់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៤ ដោយរោងចក្រផ្តល់ប្រាក់ឧបត្ថម្ភជូនកម្មករ-និយោជិតម្នាក់ៗចំនួន ២៤,១២ ដុល្លារអាមេរិក នឹងបើកជូនកម្មករ-និយោជិតនៅថ្ងៃទី០៤ ខែធ្នូ ឆ្នាំ២០២៤។

២- ទន្ទឹមនឹងនេះ រោងចក្រឯកភាពរក្សាប្រាក់រង្វាន់ការងារទៀងទាត់ ប្រាក់រង្វាន់ផ្ទាល់ខ្លួន ប្រាក់ធ្វើដំណើរ ស្នាក់នៅ នៅដដែលសម្រាប់រយៈពេលនៃការព្យួរកិច្ចសន្យាការងាររយៈពេលខាងលើនេះ។ ចំពោះប្រាក់ថ្លៃបាយថ្ងៃត្រង់ រោងចក្រនឹងផ្តល់ជូនតាមចំនួនថ្ងៃធ្វើការជាក់ស្តែង។

៤- កម្មករ-និយោជិតដែលត្រូវបានព្យួរការងារសរុប ២៦៨នាក់ ត្រូវត្រលប់ចូលធ្វើការងារវិញតាមកាលកំណត់របស់រោងចក្រ ចំពោះកម្មករ-និយោជិតណាដែលមិនត្រលប់មកធ្វើការងារតាមពេលវេលាកំណត់ រោងចក្រនឹងអនុវត្តន៍តាមបទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ក៏ដូចជាបទបញ្ញត្តិ និងច្បាប់ស្តីពីការងារ។

**បញ្ជាក់៖** កិច្ចព្រមព្រៀងនេះមានប្រសិទ្ធិភាពចំពោះកម្មករ-និយោជិតទាំងអស់របស់រោងចក្រ ខេមបូ យូនីសូល អិលធីឌី ជាមួយនឹងនិយោជកនៃរោងចក្រ ខេមបូ យូនីសូល អិលធីឌី ចាប់ពីពេលចុះហត្ថលេខានេះតទៅ។

*(ចន្លោះនេះត្រូវបានទុកអោយទំនេរ)*

ថ្ងៃចន្ទ ១១កើត ខែកត្តិក ឆ្នាំរោង ឆស័ក ព.ស ២៥៦៨

ធ្វើនៅកណ្ដាល ថ្ងៃទី១១ ខែវិច្ឆិកា ឆ្នាំ២០២៤

**ថ្នាក់ដឹកនាំសហជីព និងប្រតិភូបុគ្គលិក** | **អគ្គនាយកក្រុមហ៊ុន**

CAMBO UNISOLL LTD.
KINGDOM OF CAMBODIA

**កាង ម៉ូន សាន់**

---